មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0155**

## សម្ភាសន៍ជាមួយឈ្មោះ ញ៉ុញ សឿម ភេទប្រុស អាយុ៦០ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ ខាងកងចល័ត

## មុខងារបច្ចុប្បន្ន ៖ កសិករ

## សព្វថ្ងៃរស់នៅភូមិដើមវត្ត ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ វ៉ាន់ថាន់ ពៅដារ៉ា

## ០០ៈ៣៨ៈ០២

## ២០ទំព័រ

ដារ៉ា ៖ ជំរាបសួរខ្ញុំចង់ដឹងថាពូមានឈ្មោះអី?

សឿម ៖ ខ្ញុំឈ្មោះ ញ៉ុញ សឿម ។

ដារ៉ា ៖ ញ៉ុញ សឿម?

សឿម ៖ បាទ, ឈ្មោះដដែល មិនដូរទៅណាទេ ។

ដារ៉ា ៖ ពូមានអាយុប៉ុន្មានឆ្នាំហើយ?

សឿម ៖ ខ្ញុំមានអាយុ៦០ឆ្នាំហើយ ។

ដារ៉ា ៖ អូ ៦០ឆ្នាំហើយណ៎!

សឿម ៖ បាទ

ដារ៉ា ៖ ពូមានស្រុកកំណើតនៅភូមិណា ឃុំណា?

សឿម ៖ ខ្ញុំនៅភូមិកណ្តាលនេះអែង ។

ដារ៉ា ៖ ភូមិកណ្តាលអញ្ចឹងណ៎!

សឿម ៖ បាទ, ភូមិកណ្តាលនេះឯង ។

ដារ៉ា ៖ ភូមិកណ្តាល ឃុំ?

សឿម ៖ ឃុំព្រះនេត្រព្រះយើងនេះឯង ។

ដារ៉ា ៖ ឃុំព្រះនេត្រព្រះ ។

សឿម ៖ បាទ ។

ដារ៉ា ៖ រាល់ថ្ងៃពូរស់នៅភូមិអី ឃុំអី?

សឿម ៖ ភូមិដើមវត្ត ឃុំព្រះនេត្រព្រះ ។

ដារ៉ា ៖ ភូមិដើមវត្ត ។

សឿម ៖ ពេលបានគ្រួសារមករស់នៅភូមិនេះ ។

ដារ៉ា ៖ បាទ ។ ពូមានកូនចៅប៉ុន្មាននាក់?

សឿម ៖ កូនចៅខ្ញុំប្រាំនាក់ ។

ដារ៉ា ៖ កូនប្រាំនាក់ ។ ប្រុសប៉ុន្មាន ស្រីប៉ុន្មានពូ?

សឿម ៖ ប្រុសមួយ ស្រីបួន ។ ពីរបែកទៅនៅឯណោះ នៅនេះពីរ ។

ដារ៉ា ៖ ហើយអ៊ីគ្រួសារពូឈ្មោះអីដែរ?

សឿម ៖ ឈ្មោះ ញឹប សុខគៀត

ដារ៉ា ៖ ញឹប សុខខៀត?

សឿម ៖ ញឹប សុខគៀត ។

ដារ៉ា ៖ គាត់អាយុប៉ុន្មានឆ្នាំហើយ?

សឿម ៖ គាត់អាយុ៦១ ។

ដារ៉ា ៖ បងពូទៀតអញ្ចឹង?

សឿម ៖ បាទ ។

ដារ៉ា ៖ អត់ទោសពូ ឪពុកពូឈ្មោះអីដែរ?

សឿម ៖ ឈ្មោះ ញុញ ដៃ ។

ដារ៉ា ៖ ញុញ ដៃ ។

សឿម ៖ គាត់ខូចនៅសម័យបីឆ្នាំនោះឯង ។

ដារ៉ា ៖ អូ, គាត់ស្លាប់នៅសម័យបីឆ្នាំនោះអី ។ ចុះគាត់ស្លាប់ដោយសារអីដែរ?

សឿម ៖ ហ៎ះ?

ដារ៉ា ៖ គាត់ស្លាប់ដោយសារអីដែរ?

សឿម ៖ ទេ កាលណោះគាត់រោគចាស់ ។

ដារ៉ា ៖ រោគចាស់ជរាអី ។

សឿម ៖ បាទ ។

ដារ៉ា ៖ ចុះម្ដាយឈ្មោះអី?

សឿម ៖ ជុំ ហៀម ។

ដារ៉ា ៖ ជុំ ហៀម?

សឿម ៖ បាទ ៗ គាត់ស្លាប់នៅពេទ្យប្រាំបីនេះឯង ។

ដារ៉ា ៖ បាទ ៗ ពូមានបងប្អូនប៉ុន្មាននាក់?

សឿម ៖ បងប្អូនខ្ញុំប្រាំនាក់ ។

ដារ៉ា ៖ បងប្អូនប្រាំនាក់ ។ ចុះប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

សឿម ៖ ប្រុសពីរ ស្រីបី ។

ដារ៉ា ៖ ពូជាកូនទីប៉ុន្មាន?

សឿម ៖ ជាកូនទីប្រាំ ។

ដារ៉ា ៖ ចុះគេណ៎!

សឿម ៖ នោះហើយ ចុះគេ ។

ដារ៉ា ៖ ពៅគេណ៎ ។ ចុះកូនបងគេ ស្រីឬមួយក៏ប្រុស?

សឿម ៖ ស្រី ។

ដារ៉ា ៖ ស្រី ។

សឿម ៖ ស្រី តែគាត់ខូចហើយ ។ ខូចពីរឆ្នាំហើយ ។

ដារ៉ា ៖ ចុះបើគាត់ពៅអាយុ៦០ហើយហ្នឹង ។

សឿម ៖ បាទ ។

ដារ៉ា ៖ អញ្ចឹងកូនបងនោះ វា?

សឿម ៖ ចិតជាង ។

ដារ៉ា ៖ ចិតជាង ប៉ែតហើយណ៎ ។

សឿម ៖ បាទ, ប៉ែតហើយ ។ រាល់មកដល់ខែនេះ ប៉ែតហើយ ។

ដារ៉ា ៖ ពីមុនមកពូរៀនបានដល់ថ្នាក់ណា?

សឿម ៖ រៀនដល់ថ្នាក់ទីប្រាំពីរ ។

ដារ៉ា ៖ សាលាណាពូ?

សឿម ៖ សាលាព្រះនេត្រព្រះយើងនេះ ។

ដារ៉ា ៖ ហេតុអីបានរៀនបានថ្នាក់ប៉ុណ្ណឹង ។

សឿម ៖ ដោយសាររៀនខ្សោយពេក ប្រលងមិនជាប់ទៅ ក៏ឈប់រៀនបណ្ដោយ ។

ដារ៉ា ៖ អ៊ឺរ!

សឿម ៖ កាលប្រលងកាលណោះគឺប្រលងចូលថ្នាក់ទីប្រាំមួយ ។

ដារ៉ា :	ទៅប្រលងដល់ណា?

សឿម :	ទៅប្រលងនៅ សេរីសោភ័ណ្ឌយើងនេះ ។

ដារ៉ា :	អញ្ចឹងពូមានឱកាសទៅប្រលងគេដែរណ៎!

សឿម :	បាទទៅ ។

ដារ៉ា :	តែអត់ជាប់ ។

សឿម :	ទៅប្រលងម្ដង ពីរដង ។

ដារ៉ា :	ប្រលងពីរដង ហើយធ្លាក់ទាំងពីរដង?

សឿម :	បាទ ។ ទៅរៀនមិនរួចនេះហើយបានជាដើរថយក្រោយ ។

ដារ៉ា :	ឈប់ហើយ មកធ្វើអី?

សឿម :	មានអី ធ្វើស្រែចំការអីធម្មតា ជាមួយនឹងឪ ។

ដារ៉ា :	ជាមួយឪពុកម្ដាយហ្នឹងទៅ ។

សឿម :	បាទ ។

ដារ៉ា :	ហើយនៅក្នុងភូមិពូហ្នឹង នៅពេលដែលពូឈប់រៀនហ្នឹង មានខ្មែរក្រហមហើយនៅ? .

សឿម :	កាលណោះ នៅមិនទាន់មានចូលទេ ។

ដារ៉ា :	អត់ទាន់មានទេណ៎!

សឿម :	បាទ, កាលនោះមាននៅឆ្នាំ៧៥ , អ៊ូអត់ទេ ដូចជា ឆ្នាំ៧១ និង៧២នោះឯង ។

ដារ៉ា :	ឆ្នាំចិតប៉ុន្មានពូ?

សឿម :	ឆ្នាំ៧២ ចាប់ផ្ដើមមានខ្មែរក្រហមហើយ ។

ដារ៉ា :	ឆ្នាំ៧២ណ៎!

សឿម :	វានៅចូលមកបៀតៗហ្នឹងណា ។

ដារ៉ា :	នៅបៀតៗសិនហ្ន៎! អត់ចូលមកដល់ភូមិទេហ្ន៎ ។

សឿម :	អត់ទាន់ចូលមកដល់ភូមិទេ ។ ទាល់តែ៧៥បានចូលមកដល់បណ្ដាយ ។

ដារ៉ា :	អញ្ចឹងនៅឆ្នាំ៧២ ពួកវានៅក្នុងព្រៃ និងក្បែរភូមិអីអញ្ចឹងទៅ ។

សឿម :	បាទ ។ វានៅឆ្ងាយណា ។ នៅព្រៃរនាមយើងនេះ ។

ដារ៉ា :	ដែលមកចូលក្នុងភូមិអីម្ដងម្កាលដែរទេពូ?

សឿម :	មានចូលមក ប៉ុន្តែទាល់តែ៧៣បានមាន ។

ដារ៉ា :	ដល់ឆ្នាំ៧៣បានមានចូលមក ។

សឿម ៖ បាទ, ចូលមកវាយគ្នានៅក្នុងស្រុកយើងនេះ ។

ដារ៉ា ៖ ហើយមានចូលមកធ្វើការឃោសនា ឃោសអីដែរទេនៅក្នុងភូមិ?

សឿម ៖ កាលណោះអត់មានទេ ។ កាលនោះវាវាយហើយ ក៏វាចូលមក ។ កាលនោះ វាមានម្សៅមានគ្រប់អីអញ្ជឹងទៅណា ។ ហើយយើងក៏បេះម្សៅ បេះគ្រប់ ហើយដាក់ប្រាក់ដាក់អីចូលទៅ ឲ្យអញ្ជឹងទៅណា ។ គេយកធ្វើលេសអីអញ្ជឹងទៅណា៎ ព្រោះស្មានថាគេល្អណាស់នោះណា ។ គេជាសម្ដេចឲ្យចូលមក មានអីយើងយ៉ាប់បណ្ដោយ ។

ដារ៉ា ៖ អញ្ជឹងឆ្នាំណាពួកខ្មែរក្រហមចាប់ផ្ដើមគ្រប់គ្រង?

សឿម ៖ ឆ្នាំ៧៥ ។

ដារ៉ា ៖ ៧៥ ។

សឿម ៖បាទ, ចុះពាក់កណ្ដាល៧៥ ។

ដារ៉ា ៖ នៅភូមិពូ នៅភូមិកណ្ដាលហ្នឹងតែម្ដងហ្នឹងអី ។

សឿម ៖ បាទ ។

ដារ៉ា ៖ នៅណាភូមិកណ្ដាលពូ?

សឿម ៖ នេះនៅជិតគ្នាសោះ ។

ដារ៉ា ៖ អូ នៅក្បែរភូមិជើងវត្តនេះដែរហ្ន៎!

សឿម ៖ បាទ ។ នៅខាងលិចវត្តនេះឯង ។

ដារ៉ា ៖ អ៊ី, នៅខាងលិចវត្ត ។

សឿម ៖ខ្ញុំនៅភូមិច្រើន ។ ខ្ញុំមាននៅឯ ជ្រោកព្រីងណោះផង ។ ប៉ុន្តែកំណើតដែលកើតនៅនឹងម្ដាយឪពុកគឺនៅ ជ្រោកព្រីង, ជ្រោកសំរោង ។

ដារ៉ា ៖ ជ្រោកព្រីង , ជ្រោកសំរោង ។

សឿម ៖ កាលពីដើមមិញសម័យអសិរណ្យនោះ វាសំបូរចោរសម្បើមហើយ អញ្ជឹងគាត់មិនទាន់ហ៊ាននៅ ក៏មកទិញដីគេមកនៅភូមិ កណ្ដាល បានជាខ្ញុំមកកើតកំណើតនៅឯងនេះ ។ តែបងខ្ញុំកើតនៅណោះទាំងអស់ ។

ដារ៉ា ៖ អ៊ី! បង ៗ ទាំងអស់កើតនៅជ្រោកសំរោងនេះទេ ។ ពេលខ្មែរក្រហមចូលមកភូមិពូដឹបូងបង្អស់ តើមានសកម្មភាពអីកើតឡើងខ្លះដែរពូ?

សឿម ៖ ទេមុនដំបូងមិនមានសកម្មភាពអីទេ គ្រាន់តែឲ្យយើងជន្លៀសចេញទៅក្រៅចំនួនបីថ្ងៃ ហើយឲ្យចូលមកវិញ ។ ដល់ចូលមកវិញហើយ វាក៏ជន្លៀសទៅម៉ាសាទៀតឲ្យទៅនៅភូមិផ្សេង ។

ដារ៉ា ៖ អាជន្លៀសបីថ្ងៃហ្នឹង ដំបូងគេជន្លៀសទៅណាពូ?

សឿម ៖ ចេញទៅខាងវាលស្រែខាងយើងនេះឯង ។

ដារ៉ា ៖ អញ្ចឹង ។ អត់មានភូមិ មានឃុំអីទេហ្ន៎?

សឿម ៖ មានតែភ្នំ ហើយនៅភូមិ ស្រែះ ហើយចេញទៅតាមវាលប៉ុណ្ណោះឯង ។ ដល់វិលងបីថ្ងៃមក គេហើយចូលមកវិញ ។

ដារ៉ា ៖ ចូលមកភូមិកណ្ដាលហ្នឹងអី?

សឿម ៖ ចូលមកភូមិកំណើតវិញហ្នឹងណា ។ តែពីដើមមកខ្ញុំនៅប៉ោកព្រីង ទៅដល់ពេលអញ្ចឹងទៅខ្ញុំក៏ទៅធ្វើស្រែនៅឯណោះទៅ ។ អត់បានមកផ្ទះឯងណេះទេ ។ ផ្ទះណេះបងខ្ញុំនៅ ។

ដារ៉ា ៖ បាទ ។

សឿម ៖ ខ្ញុំនៅជាប់នៅប៉ោកព្រីងនេះ ។ ហើយជន្លៀសបានបីថ្ងៃ ចូលភូមិវិញបានតែពីរថ្ងៃ គេដេញទៅវិញទៀត ។ ចេញម្ដងហ្នេះ ពីដើមមិញ យើងអាចយកអីទៅខ្លះ ។ ដល់លើកក្រោយគ្មានបានប្រមូលអីទេ អាងតែថាមិនអីទេដឹង ក៏ទៅសឹងតែខ្លួនទទេដង ។ ដល់តែវាឈប់ឲ្យមកភូមិវិញ ហើយវាចាប់ផ្ដើមប្រមូលឥវ៉ែឥវ៉ាន់នៅកន្លែងនេះទៅ ហើយយើងនៅកន្លែងផ្សេងទៅ ចាត់ចែងឲ្យនៅតាមភូមិៗរៀងខ្លួនទៅ ។

ដារ៉ា ៖ ភូមិផ្សេងទៀតអញ្ចឹងទៅ!

សឿម ៖ បាទ, ហើយនៅម្ដុំភូមិស្រែះនេះឯង នៅក្បែរភ្នំស្រុកនេះ ។

ដារ៉ា ៖ ហើយភូមិហ្នឹង មានភូមិពីមុនមកហើយ?

សឿម ៖ បាទ មានភូមិពីមុនមកហើយ តែយើងនៅដោយឡែកគ្នា ។

ដារ៉ា ៖ ដល់ពេលយើងជន្លៀសទៅ ដូចអ្នកថ្មីទៅនៅអញ្ចឹងអី?

សឿម ៖ បាទ នៅដូចអ្នកថ្មីអញ្ចឹង ។

ដារ៉ា ៖ អញ្ចឹងនៅដោយអ្នកជន្លៀសទៅមួយក្រុមអញ្ចឹងទៅ ។

សឿម ៖ បាទៗ ។

ដារ៉ា ៖ អត់ចូលជាមួយអ្នកភូមិគេរស់នៅនោះពីមុនមកទេ?

សឿម ៖ បាទ ។

ដារ៉ា ៖ អ៊ឺ, ដាក់ដោយឡែក ។

សឿម ៖ បាទ ។ ដល់ពេលធ្វើស្រែខាងក្រោមរួច បានគេបញ្ជូលមកវិញ ។ បញ្ជូលមក ចល័តភូមិ ។ ដូចពីដើមឡើយ ខ្ញុំនៅប៉ោកពីង គេឲ្យខ្ញុំទៅនៅប៉ោកគ្លឿងឯងណោះ ឲ្យនៅដកពោតនៅឯហ្នុះ ។ ហើយនៅភូមិកណ្ដាល ក៏ដូចគ្នាអញ្ចេះឯង ។ តែគេដូរចាស់ មកនៅថ្មី ។ នៅអែបគ្នានេះឯង ។

ដារ៉ា ៖ បាទ ។

សឿម ៖ ដូចប៉ោកគ្លឿង មកនៅភូមិជើងវត្ត ហើយភូមិជើងវត្ត ទៅនៅតាប៉ែនឯណោះ ។

ដារ៉ា ៖ អញ្ជឹង ។ គេចល័តភូមិគ្នា ។

សឿម ៖ បាទគេចល័តភូមិគ្នា ។

ដារ៉ា ៖ អត់ឲ្យនៅក្នុងភូមិកំណើតហ្នឹងទេ ។

សឿម ៖ បាទ ។

ដារ៉ា ៖ កាលណោះ ពូមានគ្រួសារហើយតើអី?

សឿម ៖ បាទមានហើយ ។

ដារ៉ា ៖ ហើយពូមានគ្រួសារនៅឆ្នាំណា? រៀបការណា?

សឿម ៖ អ៊ំ, កាលហ្នុះ ខ្ញុំរៀបការនៅឆ្នាំ៧៦ ដូចជាជិតចូល៧៧ខ្ញុំមានគ្រួសារ ។ ខ្ញុំចេញទៅចល័ត ។

ដារ៉ា ៖ ដំបូងអត់មានគ្រួសារទេ ពេលដែលខ្មែរក្រហមចូលមក?

សឿម ៖ នៅ។, កាលណោះនៅលីវ ។

ដារ៉ា ៖ ពេលយើងនៅលីវអញ្ជឹង គេឲ្យយើងចូលកងអី?

សឿម ៖ កាលណោះកងកុមារ តែខ្ញុំចាស់ ដល់ពេលអញ្ជឹងទៅ គេឲ្យគោឲ្យរទេះអញ្ជឹងទៅ ឲ្យភ្ជួររាស់ជាមួយចាស់។ទៅណា ។ តែមិនបានបញ្ជូនទៅជាមួយកងកុមារទេ ។

ដារ៉ា ៖ អញ្ជឹងនៅជាមួយចាស់ៗភ្ជួរស្រែអីអញ្ជឹងទៅ ។

សឿម ៖ ដល់ពេលគេចម្រាញ់ទៅ គេដកឲ្យទៅកងយុវជនវិញ ។

ដារ៉ា ៖ ក្រុមយុវជន ។ កាលណោះ ប្រធានពូឈ្មោះអីទៅ?

សឿម ៖ មុនដំបូងនៅភូមិប៉ោកពីង គាត់ឈ្មោះតា ហិប ។

ដារ៉ា ៖ តាអី?

សឿម ៖ តា ហិប ។

ដារ៉ា ៖ តា ហិប ។

សឿម ៖ គាត់ជាចៅមេភូមិតាំងពីមុនមក ។ គាត់មេភូមិនេះឯង ។

ដារ៉ា ៖ ដល់ក្រោយមកមានផ្លាស់ប្ដូរអ្នកណាទៀតទេ?

សឿម ៖ ដល់ក្រោយមក គេយកអ្នកផ្សេង ។ ដល់ចូលមកសម័យបីឆ្នាំនេះមក គេយកអ្នកផ្សេង ។ អ្នកដែលមានជាប់និន្នាការពីមុន គេអត់យកទេ ។ គេយកអ្នកថ្មី ។

ដារ៉ា ៖ អញ្ចឹងដល់ពេលពូទៅជាកងចល័តនោះ តើពូទៅមានគ្នាប៉ុន្មាននាក់ដែរ?

សឿម ៖ ទេគ្នាច្រើនដែរ រាប់បញ្ចូលអ្នកក្នុងភូមិ ហាហុកសិបនាក់ ។ ប្រមូលចល័តជុំគ្នាអញ្ចឹងទៅ ។ បើក្រុមចល័តយុវជនកុមារតាមភូមិ គេដាក់នៅម៉ាភូមិអញ្ចឹងទៅ ។ ដល់ពេលទៅចល័តមួយតំបន់៥ចូលគ្នា ។

ដារ៉ា ៖ ហើយការងារកងចល័តហ្នឹង ចូលទៅអ្នកណាជាមេកង?

សឿម ៖ អូ ប្រធានកងជាច្រើនណាស់ ចម្រុះគ្នាអញ្ចឹងទៅ ។ ហើយក្មេចអស់ទៅខ្លះទៅ ហើយអាខ្លះក៏ងាប់ទៅអស់ទៅ ។ ប៉ុន្ដែ ប្រធានស្លាប់រស់មានតែប្រធានឈ្មោះ តាវ៉ាល់ៗនេះឯង ។

ដារ៉ា ៖ អូ តាវ៉ាល់ហ្នឹងជាអ្នកគ្រប់គ្រងមួយចល័តតំបន់នេះឬ?

សឿម ៖ ណោះឯង ។

ដារ៉ា ៖ កាលណោះតំបន់ប៉ុន្មានទៅ?

សឿម ៖ តំបន់៥ ។

ដារ៉ា ៖ ហើយអឺ កងចល័តពូដំបូង ធ្វើការនៅកន្លែងណា?

សឿម ៖ ដំបូងនៅទំនប់ កំពោលស្រេះ យើងនេះ ។

ដារ៉ា ៖ នៅទំនប់ កំពោលស្រេះ ។

សឿម ៖ ដល់នៅ កំពោលស្រេះ រួច ក៏ចាប់ទៅនៅ ស្ពាច ខ្សែខាងលើនេះណ៎ ។

ដារ៉ា ៖ កំពោលស្រេះហ្នឹង ទំនប់ធំតើអីពូ?

សឿម ៖ បាទៗ ទំនប់ធំ ។ ទំនប់ធំណាស់ ស្មើថ្នល់យើង ទទឹងប្រាំម៉ែត្រ ជម្រៅទៅក្រោមដប់ម៉ែត្រ ។

ដារ៉ា ៖ ហើយលើកនៅហ្នឹងទៅ?

សឿម ៖ បាទលើកនៅហ្នឹងទៅ ។

ដារ៉ា ៖ ការលើក ការអីហ្នឹង គេដាក់ផែនការអីយ៉ាងម៉េចទៅ?

សឿម ៖ បាទ ផែនការ គេដាក់ម៉ែត្រគីប ។

ដារ៉ា ៖ ម៉ែត្រគីប ។ ជាក្រុម ឬមួយជាបុគ្គលពូ?

សឿម ៖ ជាបុគ្គលម្នាក់ៗ ។ ប៉ុន្តែ ជាក្រុមគេដាក់ ឧបមាថាក្រុមយុវជនអញ្ជឹងទៅ គេទទួលខុសត្រូវម៉ាក្រុមគ្នាគេអញ្ជឹងទៅណា ។

ដារ៉ា ៖ បាទ ។ ប៉ុន្តែ ដល់ពេលលើកដី លើកអី ជាបុគ្គល ដោយវាស់ម៉ែត្រ ។

សឿម ៖ បាទ, ជាបុគ្គល ហើយវាស់ម៉ែត្រ ។ ម្នាក់ បើថាកម្លាំងវាធំ ម្នាក់ប្រាំម៉ែត្រក្នុងមួយថ្ងៃ ។

ដារ៉ា ៖ អីយ៉ា!

សឿម ៖ បើវាងដំទើរតិច គេឲ្យបីម៉ែត្រ ។

ដារ៉ា ៖ បាទ ។ ចុះសម្រាប់ពូប៉ុន្មានម៉ែត្រ?

សឿម ៖ ខ្ញុំប្រាំម៉ែត្រ ។

ដារ៉ា ៖ អូ!

សឿម ៖ លើកពេញមួយល្ងាច ។

ដារ៉ា ៖ លើករួចដែរពូ?

សឿម ៖ រួច ។

ដារ៉ា ៖ រួចណ៎ ។

សឿម ៖ លើកពេញមួយល្ងាចតែម្ដង ។

ដារ៉ា ៖ ចុះទៅលើកពីម៉ោងប៉ុន្មានទៅ?

សឿម ៖ ម៉ោងប្រាំមួយព្រឹក តែម៉ោងប្រាំពីរឡើងនាំគ្នាចេញ ។ តែដល់គេដាក់ផែនការឲ្យហើយក៏នាំគ្នាទៅតាំងម៉ោងប្រាំមួយព្រឹក ។

ដារ៉ា ៖ ដល់មកប៉ុន្មាន?

សឿម ៖ ដល់ម៉ោងដប់ ដប់មួយអីបានហូបបាយ ។ បាយរួចសម្រាកបានកន្លះម៉ោងអី ក៏ឡើងទៅធ្វើការវិញទៅ ។

ដារ៉ា ៖ រៀងរាល់ថ្ងៃអញ្ជឹងទៅ?

សឿម ៖ បាទ ។

ដារ៉ា ៖ ហើយការហូបចុកហ្នឹងគ្រប់គ្រាន់ដែរទេ?

សឿម ៖ ចុះកាលណោះវាមធ្យម វាមិនទាន់ជុនដាបទេចំពោះកងចល័តនោះ ។ ដល់ក្រោយៗមកទើបវាខ្លាំង វាជុនដាបខ្លាំង ។ មុនដំបូងដូចខ្ញុំ បាយវាគ្រាន់បើដែរ ។ ដល់មកដល់ក្រោយៗ

វាដុនដាបមែនទែន ។ ដូចថាវាវឹតយើងណា ។ មុនដំបូងដូចថាវាសមរម្យហើយ ដល់ក្រោយៗមក ។

ដារ៉ា : ដល់ពេលចេញពីហ្នឹងទៅ ទៅណាទៀត?

សឿម : ដល់ពេលបានគ្រួសារហើយ ខ្ញុំក៏ត្រឡប់មកនៅភូមិវិញ ។

ដារ៉ា : បានគ្រួសារនៅឯណា?

សឿម : នៅកំបោលស្រះហ្នឹងឯង ។

ដារ៉ា : ការបានតាមម៉េចទៅ?

សឿម : តាមការស្នើសុំ ។

ដារ៉ា : ពូស្នើសុំគេតែម្ដង?

សឿម : បាទ ។ ដូចថាសុំគ្រួសារខ្ញុំអញ្ចឹង ឲ្យម៉ែឪខ្ញុំនិយាយឲ្យទៅ ប្រាប់ប្រធានក្រុមប្រធានកងទៅ ។ រួចហើយគេចូលតាមក្រោយ ។ អញ្ចឹងគេទាក់ទងតាមក្រោយ ។

ដារ៉ា : អញ្ចឹងពូស្គាល់គ្រួសាររបស់ពូហ្នឹងមុននឹងទៅលើកទំនប់ហ្នឹង ឬក៏ស្គាល់ថាក្រោយ?

សឿម : ស្គាល់មុន ព្រោះនៅជាប់ភូមិគ្នានេះឯង ។

ដារ៉ា : អ៊ី, នៅភូមិនេះឯង ។

សឿម : បាទ, ម៉ែឪអីស្គាល់គ្នា ។

ដារ៉ា : ដល់ពេលអញ្ចឹងគ្រួសារពូទៅលើកទំនប់ជុំគ្នាដែរ?

សឿម : បាទ, ទៅទាំងអស់គ្នា ។

ដារ៉ា : ជុំគ្នា ។

សឿម : រៀបការរួចហើយបានទៅជុំគ្នា ។

ដារ៉ា : ចុះពូស្នើតាមរយៈម៉េចទៅ?

សឿម : ស្នើតាម ដូចថាគេគ្រប់គ្រងដោយប្រធាននារីអញ្ចឹងទៅ យើងឲ្យគេទាក់ទងប្រធាននារីគេ ។ ប៉ុន្តែ អារឿងគ្រួសារខ្ញុំ ម៉ែឪខ្ញុំនិយាយគ្នារួចមុនស្រេចហើយ ។

ដារ៉ា : អ៊ី, ឪពុកម្ដាយសងខាងដឹងរឿងអស់ហើយ ។

សឿម : បាទ ។ គ្រាន់តែយើងឲ្យគេទៅទាក់ទងឲ្យ ។

ដារ៉ា : នៅក្នុងឆ្នាំណាទើបពូការ?

សឿម : នៅឆ្នាំ៧៧ ។

ដារ៉ា : ការនោះមានឪពុកម្ដាយទៅចូលរួមដែរ?

សឿម ៖ ទៅដែរ តែចាស់ៗគ្រាន់តែទៅអើតៗ ។

ដារ៉ា ៖ ការនោះគេធ្វើពិធីអីដែរទេ?

សឿម ៖ ទេ, គេធ្វើពិធីធម្មតាទេ ដោយសារតែច្រើនគូទៅ ។

ដារ៉ា ៖ ក្នុងពេលដែលពូការហ្នឹងអី?

សឿម ៖ បាទ, ក្នុងមួយថ្ងៃតែម្ដង ច្រើនគូណាស់ ។

ដារ៉ា ៖ ពេលការហើយ គេឲ្យនៅជាមួយគ្នាជាប្ដីប្រពន្ធតែម្ដងអីពូ?

សឿម ៖ បាទ នៅជាប់គ្នា ។

ដារ៉ា ៖ ចុះការចេញទៅធ្វើការ ធ្វើអីនោះម៉េចទៅ?

សឿម ៖ ចេញទៅធ្វើការ ក៏ទៅជុំគ្នាអញ្ចឹងទៅ ។ តែចល័ត បំបែកគ្នាអញ្ចឹងទៅ ។

ដារ៉ា ៖ ដល់បានគ្រួសារអញ្ចឹង តើពេលហូបចុកហ្នឹងម៉េចទៅ?

សឿម ៖ ពេលហូបចុក ហូបជាក្រុមជាមួយគ្នាអញ្ចឹងទៅ ។

ដារ៉ា ៖ ក្រុមជាមួយគ្នាហ្នឹង ។

សឿម ៖ ដូចថាគេបញ្ចូលក្រុមវ័យកណ្ដាលហ្នឹងណា ។ យើងបានគ្រួសារហើយ គេឲ្យនៅមួយក្រុមទៅ ហូបមួយក្រុមទៅ ។

ដារ៉ា ៖ អ្នកដែលមានគ្រួសារអញ្ចឹងទៅ ។

សឿម ៖ នៅមួយក្រុមគ្នាឯង ។

ដារ៉ា ៖ បាទ ។ ពេលហ្នឹងពូមានកូនដែរ?

សឿម ៖ អត់មានទេ ។

ដារ៉ា ៖ អត់មានទេហ្ន៎ ។

សឿម ៖ បាទ, ខ្ញុំមានពេល៧៩ចប់ហើយ ។

ដារ៉ា ៖ ចប់ហើយបានមានកូន ។ ហើយក្រោយមក ពូមានបានចល័តទៅណាទៀតទេ ។

សឿម ៖ ក្រោយមកមានតែចល័ត នៅហ្នឹងភូមិកំណើត ។

ដារ៉ា ៖ មកភូមិកំណើតវិញ ។ គេឲ្យធ្វើអីវិញនៅភូមិ?

សឿម ៖ ធ្វើស្រែដែរ ។

ដារ៉ា ៖ ធ្វើស្រែ ។

សឿម ៖ ធ្វើស្រែកាន់គោរទេះ ។

ដារ៉ា ៖ ចុះពេលមកដល់ភូមិវិញ ការហូបចុកនោះម៉េចដែរ ។

សឿម ៖ ទេ កាន់តែយ៉ាប់ហើយ ។ កន្លែងភូមិកាន់តែយ៉ាប់មែនទែន ។

ដារ៉ា ៖ យ៉ាប់ហ្នឹងដោយសារ?

សឿម ៖ យ៉ាប់អារឿង បបរមួយខ្វះ ម្នាក់បានមួយវែកទៅណា ។ មានតែស្រវេស្រវា រកខ្ចួនឯងខ្វះ ។

ដារ៉ា ៖ រកហ្នឹង រករបៀបណា?

សឿម ៖ រកលួចលាក់ៗ (សើច)

ដារ៉ា ៖ អត់ដោយសារខ្វះអាហារ ខ្វះស្បៀងឬក៏យ៉ាងម៉េច?

សឿម ៖ ទេ វាខ្វះដោយសារវាមិនឲ្យហូបផង ។ ដល់ការដែលធ្វើបានដាវបបនោះ វាមានច្រើន ប៉ុន្តែគេដញ្ជូនទៅណាអស់ទៅ ។ វាមិនទុកឲ្យយើងហូបគ្រប់គ្រាន់ ។

ដារ៉ា ៖ បាទ ។

សឿម ៖ ធ្វើស្រែបានពេញណាពេញណីហ្ន៎ ។ ក្នុងព្រះវិហារនេះ វត្តនេះដាក់សុទ្ធតែស្រូវ ។ តែដល់ទីបញ្ចប់មិនដឹងទៅណាអស់ ។ នៅតាមភូមិតិចៗទៅ វាក៏ឲ្យយើងស៊ីបន្តយបណ្តោយ ។

ដារ៉ា ៖ បាទ, អញ្ចឹងពូបានទៅលើកទំនប់ត្រពាំងថ្មដែរ?

សឿម ៖ ទៅ ។

ដារ៉ា ៖ ទៅរយៈពេលប៉ុន្មាន?

សឿម ៖ កន្លះខែ ។

ដារ៉ា ៖ នៅក្នុងឆ្នាំណាពូ?

សឿម ៖ អត់បានចាំទេ ។

ដារ៉ា ៖ ចុះពូបានគ្រួសារ....

សឿម ៖ នៅឆ្នាំ៧៧ ហូនៅឆ្នាំ៧៨ ។

ដារ៉ា ៖ ចូល៧៨បានទៅ?

សឿម ៖ បាទ ។

ដារ៉ា ៖ អញ្ចឹងពូរៀបចំគ្រួសារហើយបានទៅ....

សឿម ៖ បាទ, រៀបចំគ្រួសារហើយៗ បានទៅលើក ។

ដារ៉ា ៖ ទៅដល់ឃើញទំនប់នោះយ៉ាងម៉េចដែរ.? ទៅដល់ដំបូងណាពូ?

សឿម ៖ ទៅដល់ដំបូង គេឲ្យតម្រង់មួយសាទៅ រួចទៅដើងទំនប់ទៀត ឆ្ងាយទៅដល់ព្រំដែនថៃឯលិចនោះណា ខាងដូណូយហ្នឹងណា រួចពីណោះមក ក៏មកដល់សំរោងយើងឯណេះវិញ

នៅខាងជើងទំនប់ដែលយើងលើកនោះទៀត។ នៅក្បែរកូនខ្វែង។ ដល់លើកតម្រង់មក ទៀត ខ្ញុំអត់យកអាណោះ ខ្ញុំក៏ចល័តមកវិញ ហើយគេឲ្យទៅមួយសាទៀត គេយកទំនប់ចាស់យើងវិញ អាងបុរាណចាស់ពីដើម។ ដល់ពេលគេឲ្យមក លើកតបណ្តោយ។ អត់បានយកអាខ្ញុំតម្រង់នោះទេ។

ដារ៉ា : មនុស្សម្នាប៉ុន្មាននាក់ទៅដែលទៅលើក?

សឿម : អូ ច្រើនណាស់ រាប់មិនអស់ទេ។ ព្រោះកាលលើកកាលណោះ ខ្ញុំមួយចល័តតំបន់នោះមិនតិចគ្នាទេ។ ច្រើនណាស់។

ដារ៉ា : ប្រហែលជាប៉ុន្មានក្នុងមួយចល័តតំបន់របស់ពូ?

សឿម : អូរាប់ពាន់នាក់ដាង។ ប្រាំម៉ឺន អូរាប់ម៉ឺនហ្នឹ!

ដារ៉ា : ចុះបើនិយាយរាប់ម៉ឺន មនុស្សមិនណែនតាន់តាប់ទៅហើយទេ។

សឿម : ណែននោះឯង ដាក់ទៅជាប់គ្នារជីននោះឯង ងងឹតឈឹង។ ចុះបណ្តោយច្រើននោះ។

ដារ៉ា : ចុះបណ្តោយហ្នឹងប៉ុន្មានម៉ែត្រ?

សឿម : ច្រើនណាស់។ បណ្តោយពីត្រពាំងថ្ម ទៅឯណោះ ច្រើនណាស់ ចូលដប់គីឡូក៏មិនដឹង។ ច្រើនហ្នឹងឯង ឆ្ងាយណាស់។

ដារ៉ា : ចុះការហូបចុកអីយ៉ាងម៉េចទៅពូ?

សឿម : ការហូបចុះកាលណោះនៅកងចល័ត វាមានខើចខ្វះ តែហូបគ្រាន់។ តែនៅពេលដែលខ្ញុំចុះមក វាបន្ថយនោះ ឃើញយ៉ាប់។ កាលពេលជំនាន់ខ្ញុំនៅ គេមានពេលបីដង។ តែដល់ពេលដែលខ្ញុំមកនៅនេះវិញ នោះវាចាប់ផ្តើមខើចហើយ យ៉ាប់ពេញចឹងហើយ។

ដារ៉ា : ចុះរស់នៅម៉េចទៅដល់ពេលមានមនុស្សច្រើនពាក់អញ្ចឹង?

សឿម : ដល់ច្រើនអញ្ចឹង ក៏តាមដំណើរវាទៅ ព្រោះខ្លាចផងអីផងទៅ បេះតែតស៊ូទៅ។

ដារ៉ា : រស់នៅយ៉ាងម៉េចទៅនៅហ្នឹង? រស់នៅជាប់នឹងទំនប់តែម្តងឬយ៉ាងម៉េច ក៏នៅឆ្ងាយៗពីហ្នឹង?

សឿម : បាទ, អត់ឆ្ងាយទេ នៅកៀនទំនប់នោះឯង។ លើកជារួមទៅ។

ដារ៉ា : ដេកពួនអីនៅហ្នឹងទៅ?

សឿម : បាទៗ នៅដេកនោះ អីនោះទៅ។

ដារ៉ា : ហើយគេធ្វើជារោងជាអីអញ្ចឹងទៅ។

សឿម ៖ បាទ ធ្វើជារោងជាអីទៅ ហើយដេកទៅ ជុំគ្នាអញ្ចឹងទៅ ។ នារី យុវជនមួយចម្ងាងទៅក្នុងរោងមួយទៅ ។

ដារ៉ា ៖ ចុះទឹកភក់អីម៉េចដែរ?

សឿម ៖ ទឹកក៏ប្រើប្រាស់ពីក្នុងអូរ ។ នៅណោះវាសំបូរទឹក ។ ទឹកអូរមានស្រាប់ ។ ហើយបើកន្លែងណាគឺងតែង គេដាក់ទឹកឲ្យ ។

ដារ៉ា ៖ គេដឹកចែកទឹកដឹកអញ្ចឹងទៅ?

សឿម ៖ បាទ ។ ដឹកទឹកក្បែរៗ ទឹកណាជិត គេជញ្ជូនឲ្យយើងអញ្ចឹងទៅ ។

ដារ៉ា ៖ ពូទៅបានរយៈពេលប៉ុន្មានឆ្នាំប៉ុន្មានខែដែរ?

សឿម ៖ ខ្ញុំបាននៅត្រពាំងថ្មប្រហែលកន្លះខែ ។ ដល់ពេលគេដកខ្ញុំមកក្រោយវិញ អញ្ចឹងគេផ្លាច់ចេញទៅទៀត ។ ដល់ពេលខ្ញុំចេញមក គេបញ្ចូលអ្នកក្រោយទៅណោះ មានតាំងអ្នកចល័តតាមភូមិ យុវជនកុមារតាមភូមិអីទៅអស់ ។ គេថែមទៀត ។

ដារ៉ា ៖ គេបញ្ជូនទៅថែម ។

សឿម ៖ បញ្ជូនទៅថែម ច្រើនមែនទែន ។ តែកាលណោះខ្ញុំថយមកវិញ ។ តែមិនទាន់បានថយភ្លាមទេ ព្រោះគ្រួសារខ្ញុំកាលណោះ គេឲ្យគាត់ដេរខោអាវសិន ។ ដល់ពេលមានបញ្ហាទៅ គេដកខ្ញុំឲ្យមកនៅភូមិ ។

ដារ៉ា ៖ មានបញ្ហាអីគេទៅ?

សឿម ៖ មានបញ្ហាទំនាស់ ទាស់គ្នាទៅ ក៏គេដកមកនៅក្នុងភូមិ ។

ដារ៉ា ៖ ទាស់ជាមួយអ្នកណាវិញ?

សឿម ៖ ជាមួយប្រធានក្រុម តែមិនដឹងអ្នកណាទេ ព្រោះចាំមិនសូវច្បាស់ដែរ ។ ដល់ពេលគេដកទៅ....

ដារ៉ា ៖ ដកដោយទាំងពូដែរ?

សឿម ៖ ទេខ្ញុំនៅឯណោះផ្សេងទៀតទេ ។ ដល់ខ្ញុំពេលគ្រួសារបានមកហើយ ខ្ញុំក៏តាមគាត់ទៅៗ ។

ដារ៉ា ៖ គេឲ្យមក? អ្នកណាគេអនុញ្ញាតឲ្យមក?

សឿម ៖ ទេ, មិនមានអ្នកណាឲ្យមកទេ ។ ដោយសារគ្រួសារមកយើង ទៅដូចថាវាមិនអី ។ គេដកហើយ ក៏មកនៅហ្នឹងកន្លែងនោះទៅ ។

ដារ៉ា ៖ លើកនៅត្រពាំងថ្ម ពូនៅក្រោមការគ្រប់គ្រងរបស់នរណាទៅ?

សឿម ៖ ខ្ញុំកងនៅក្រោមគាត់ គាត់នៅក្រុមធំហ្នឹងឯង ក្រុមកម្មាភិបាល ។ កាលមួយសេរីខ្ញុំនេះ ក្រុមប្រធានកងអត់អាចបញ្ហាបានទេ ត្រូវជួយលើក ជួយសែងគ្នាទាំងអស់ ។ ដល់ក្រោយៗមកទៀត មិនដឹងគេ ធ្វើម៉េចទេ ។ កាលដែលគាត់នៅចល័តជាប់នោះ អត់មាននរណាប្រធានក្រុមដើរចន្លុលបញ្ជាបានទេ ត្រូវកាន់បន្ទីទាំងអស់គ្នា ។

ជាតា ៖ ចុះកាលពីពូនៅហ្នឹង អត់លើកខ្លួនឯងទេ?

សឿម ៖ លើក! លើកប្រាំម៉ែត្រ ។ វែងដូចគ្នា ដូចយុវជន កងនារី ដូចគេដូចឯង ។ ប្រធានក្រុមមែនតែត្រូវលើកដូចគ្នា ។

ជាតា ៖ ចុះពូធ្វើម៉េចមានពេលដើរមើលគេ បើតាមធម្មតាពូលើកប្រាំម៉ែត្រដែរ?

សឿម ៖ ទេ, ខ្ញុំមិនបាច់ដើរមើលគេទេ ។ ក្រុមខាងណោះ គេដើរមើលក្រុមគេផ្សេង ។ ក្រុមយើងដូចក្រុមកម្មាភិបាលនេះ ជួយលើកគ្នាផ្សេង មួយបក្សៗ ។ មានគេត្រួតពីលើខបមាថាយើងក្រុមកម្មាភិបាលអញ្ចេះ មានគេត្រួតពីលើខ្ញុំមួយទៀត អញ្ចឹងណា ។ គេមើលយើង ធ្វើមិនធ្វើ ។

ជាតា ៖ អញ្ចឹងពូធ្វើកម្មាភិបាល ដូចតែប្រជាជនដែរ?

សឿម ៖ បាទ, ដូចតែគ្នា ។

ជាតា ៖ អញ្ចឹងកម្មាភិបាល និងប្រជាជនខុសគ្នាយ៉ាងម៉េចទៅ?

សឿម ៖ ខុសគ្នា បើគេកម្មាភិបាលធំ គេមិនសូវធ្វើការប៉ុន្មានទេ ។

ដារ៉ា ៖ ចុះការហូបចុកអីខុសគ្នាដែរអី?

សឿម ៖ ការហូបចុកខុសឆ្ងាយ ។

ដារ៉ា ៖ អញ្ចឹងពូនៅក្នុងកងកម្មាភិបាលអញ្ចឹង ហូបគ្រាន់បើទេណ៎?

សឿម ៖ ទេ, កាលជំនាន់ខ្ញុំនោះ ការហូបចុកវាធម្មតាអញ្ចឹងឯង ។ កងចល័ត កូនក្រុម កូនអីក៏ហូបដូចតែគ្នា ។ តែដល់ពេលក្រោយមកមិនដឹងយ៉ាងម៉េចទេ ព្រោះកាលជំនាន់ខ្ញុំនោះ បើគេថាបីដង មានមួយអាទិត្យបន្ថែមម្តង អាណោះកាលជំនាន់ខ្ញុំ ។ មានមែន ។ កាលណោះខ្ញុំលើកស្នាច់ ធ្វើទំនប់ ម្នាក់កន្លះគីឡូក៏មិនដឹង ហូបមិនអស់ ។ កាលណោះគេបំប៉នមែនទែនណាកងចល័ត ។ តែមកប៉ែកខាងភូមិឯងណោះ វេទនា ។

ជាតា ៖ គេបំប៉ននោះ បំប៉នតែកម្មាភិបាលតើអីពូ?

សឿម ៖ ទេ មួយក្រុមចល័តនោះទាំងអស់គ្នា មិនថាកម្មាភិបាល មិនថាអីទេ ។ ប៉ុន្តែ វាខុសគ្នាត្រង់អ្នកហូបតិចឬច្រើនប៉ុណ្ណោះឯង ។ ប៉ុន្តែបានហូបគ្រប់គ្នា ។ នេះកាលដំនាន់ខ្ញុំ ។ ទាល់តែមកក្រោយទៀតតើបានវាវេទនា ។

ដារ៉ា ៖ ចុះពូចេញពីត្រពាំងថ្មមកភូមិវិញបានរយៈពេលប៉ុន្មានបានបែកវៀតណាមចូលមក?

សឿម ៖ រយៈពេលមួយឆ្នាំដាង ។

ដារ៉ា ៖ អញ្ចឹងមានន័យថាពូទៅត្រពាំងថ្មនៅឆ្នាំ៧៧?

សឿម ៖ ណោះឯង នៅឆ្នាំ៧៧ ៧៨ ។ អាកន្ទុយឆ្នាំ៧៧ណោះឯង ។

ជាតា ៖ អញ្ចឹង ទំនប់ហ្នឹងទើបហ្នឹងចាប់ផ្ដើមឆ្នាំ៧៧ទេអញ្ចឹង?

សឿម ៖ ណោះឯង ។

ដារ៉ា ៖ កាលពូទៅដល់នោះ ទំនប់ហ្នឹងមាន....

សឿម ៖ ទំនប់នោះវាស្អាប់ចាស់បុរាណណាំ ជាអាងបុរាណពីដើម ។

ជាតា ៖ អ៊ី គេលើកថ្មីពីលើហ្នឹង!

សឿម ៖ គេលើកថ្មីពីលើ ។ ពីដើមម៉េច ដូចខ្ញុំនិយាយប្រាប់មុនអញ្ចឹងឯងថា គេឲ្យតម្រង់ទៅខាងជើង តែខ្ញុំអត់ទៅ បានគេយកមកខាងនេះវិញ ។ ខ្ញុំដើរតម្រង់រយៈពេលមួយខែបានចប់ត្រឡប់ព្រំប្រទល់តំបន់ទៅដល់ដូណូយជាប់ព្រំដែនថៃ ។

ដារ៉ា ៖ នៅត្រពាំងថ្មហ្នឹង មានអ្នកឈឺថ្កាត់អីទេពូ?

សឿម ៖ អារឿងឈឺថ្កាត់នោះ វាមិនដែលមានសេសទេ ។ វាមានហើយ មិនដែលអត់ទេ ប៉ុន្តែស្លាប់នោះវាច្រើនពេកហើយ ។

ដារ៉ា ៖ ស្លាប់នោះ ស្លាប់ដោយសារអីដែរ?

សឿម ៖ ចុះ អាណាវាហឹត់ហេវ កម្លាំងវាតូច បាយមិនបានគ្រប់គ្រាន់ទៅ ផ្សំគ្នាទាំងអស់នេះឯង ។ ដល់ថាកម្លាំងវាខ្សោយផងទៅ ហើយមានជំងឺតិចតួចផងទៅ ក៏ទៅបណ្ដោយ ។

ដារ៉ា ៖ ដល់ស្លាប់អញ្ចឹងទៅ តើមានប្រធានក្រុមប្រធានអីរាយការណ៍អីទេពូ?

សឿម ៖ បាទ, រាយការណ៍ទៅឲ្យប្រធានពេទ្យ ប្រធានអីគេអញ្ចឹងទៅ ។ ដល់តែស្លាប់ហ្វើ អញ្ចឹងក៏យកទៅកប់ទៅ ។ សម័យណោះវាពិបាកណាស់ ។

ដារ៉ា ៖ ស្លាប់ច្រើនដែរពូ?

សឿម ៖  ទេ, វាមិនមែនច្រើនណាស់ណាទេ។ ប៉ុន្តែបើថាសម្លាប់វិញ ក៏យូរៗម្តង។ បើស្លាប់ច្រើនប៉ុណ្ណោះ មិនរស់នៅច្រើនដល់សព្វថ្ងៃនេះទេ។ អានេះតាមខ្ញុំពិចារណាណា៎។ អាណោះវាដោយរោគគាំរយើងវាខ្សោយផង។

ជាតា ៖ ដល់ពេលស្លាប់អញ្ចឹង ខ្មោចគេយកទៅណាវិញពូ?

សឿម ៖  ខ្មោចក៏យកទៅកប់ក្នុងព្រៃអីទៅ។

ជាតា ៖  ជិតៗហ្នឹងអី?

សឿម ៖  ណោះហើយ។ ស្លាប់ណាក៏ចោលឲ្យតែឆ្ងាយពីកន្លែងនៅ។ អ្នកណាស្លាប់នៅកន្លែងធ្វើការក៏យកទៅកន្លែងពេទ្យ។

ដារ៉ា ៖  ពេលពូត្រឡប់មកភូមិស្រុកពូវិញ គេឲ្យពូធ្វើអីវិញទៀត?

សឿម ៖  ខ្ញុំនៅខាងក្នុងរាស់ ធ្វើស្រែអីធម្មតា ដាំដំណាំអីខ្លះទៅ។ មានតែប៉ុណ្ណោះឯង។ ស្លូងដកអីមានតែប៉ុណ្ណោះឯង។

ដារ៉ា ៖  ចូលមកដល់ភូមិវិញ អ្នកណាជាប្រធានភូមិប្រធានអី?

សឿម ៖  មកដល់ភូមិនោះ ប្រធានភូមិ.....អូភ្លេចឈ្មោះប្រធានភូមិនោះទៀត ដោយសារផ្លាស់ច្រើនមួយតា ហិន មួយនោះ អាក្រោយមកទៀតដែលថាតឹងតែងណាស់នោះឈ្មោះ ស៊ិន។

ដារ៉ា ៖  ឈ្មោះ ស៊ិន។

សឿម ៖  បាទ។ នោះឯងមហាតឹងហើយ។

ដារ៉ា ៖  ស៊ិន ហ្នឹងមកពីខាងណា?

សឿម ៖  មកពីខាងណោះឯង គេហៅស្អីទេ។ គេហៅបច្ចិមអញ្ចឹងឯង។

ដារ៉ា ៖  បច្ចិម។

ជាតា ៖ ខ្ទង់ប្រហែលឆ្នាំណាដែលតា ស៊ិន ហ្នឹងមក?

សឿម ៖  ខ្ទង់ប្រហែលឆ្នាំ៧៨៩!

ជាតា ៖ ឆ្នាំកៅ អូ៧៨!

សឿម ៖  ឆ្នាំ៧៨។ កាលណោះ ពួកនារីផង អីផង។ កាលណោះគេមកក្តាប់ហើយតឹងតែងណាស់។

ដារ៉ា ៖  តឹងរបៀបម៉េចទៅពូ?

សឿម ៖  បាទ តឹងតែងច្បាប់ទម្លាប់ មិនឲ្យហូបច្រើន វាបង្ខិតបង្ខំបយើងហ្នឹងណា។

ជាតា ៖ មិនមែនគេបន្ទឹង ដោយបន្ថែមការងារឲ្យច្រើនទេអីពូ?

សឿម : អាច្រើនរឿងការងារណោះ វាពេញបបូរណ៍ហើយ តែអាម្ហូបអាហារនេះវាចេះតែបន្ថយ យើងទៅណា ។ បន្ទឹងយើងមិនឲ្យដើររកចេញទៅឯណាឯណីទៀតទៅណា ។ កាលនៅជាមួយប្រធានភូមិមុនៗនោះ យើងអាចឆ្លៀតទៅគោទៅអី ទៅស្រែបង់ត្រីអីបានស៊ីខ្លះណា ។ ដល់ក្រោយមក គេបន្ទឹង ព្រោះគេសុទ្ធតែប្រធានមកពីឆ្ងាយ ។ ពីដើមមិញ ស្រុកភូមិប្រធានភូមិយើងហ្នឹងធូរ ។ យើងអាចឆ្លៀតឆ្លករកបាន ។ ដល់គេមកពីចម្ងាយមក យើងម៉េចហ្នឹងស្គាល់គេ ដល់អញ្ចឹងគេពឹតយកៗ ។

ដារ៉ា : បើនិយាយពីទិដ្ឋភាពនៅខាងត្រពាំងថ្មវិញអាចធៀបបានហ្នឹងព្រឹត្តិការណ៍ស្អីមួយបានទេពូ?

សឿម : អីយ៉ាង ប្រៀបធៀបមិនបានទេ មនុស្សដែលថាលើកទំនប់នេះ ។ វាច្រើនណាស់ ។ លើកកល់ៗលើគ្នាអញ្ចឹងទៅ ។ រូបភាពណោះមើលទៅវាអស្ចារ្យណាស់ ។

ជាតា : រាប់ម៉ឺននាក់ ។

សឿម : នោះឯង រាប់ម៉ឺននាក់ ។

ដារ៉ា : ចុះគេគ្រប់គ្រងម៉េចទៅ?

សឿម : ទេ គ្រប់គ្រងគេចាត់ដោយឡែក ដូចខ្ញុំនិយាយមុនអញ្ចឹងឯង ។ ឧបមា ក្រុមកុមារ ក្រុមកុមារផ្សេង ។ ក្រុមយុវជនផ្សេង ។ ក្រុមវ័យកណ្តាលផ្សេង ។ ហើយចេញពីភូមិនេះទៅតាមភូមិផ្សេង ។ ដាក់មួយក្រុមៗផ្សេងគ្នា ។

ជាតា : អញ្ចឹងកុមារក៏ជួយលើកទំនប់ហ្នឹងដែរ?

សឿម : នោះឯង ។ កុមារត្រឹមអាយុ១៥ឆ្នាំ ។ វាមិនទាន់ដល់ពេញយុវជនប៉ុន្មានហ្នឹងណា ។

ដារ៉ា : បាទ ។ ចូលរួមលើកដែរ ។

សឿម : ដល់អាត្រឹម១០ឆ្នាំនោះ វាធ្វើការមិនពេញកម្លាំងអីទេ ។ បើឲ្យវាប្រាំម៉ែត្រ វាធ្វើហើយតែមួយម៉ែត្រអីទៅណា ។ វាមានគ្នាចូលរួមគ្នា ។

ដារ៉ា : បើនិយាយពីរបប ប៉ុល ពត នេះតែម្តង តើពូអាចចង់ចាំអីគេខ្លាំងជាងគេក្នុងរបបខ្មែរក្រហមហ្នឹងណា?

សឿម : (សើច) បើនិយាយពីការចង់ចាំនោះ វាចង់ចាំមួយសព្វនោះឯង ។ អារឿងបង្អត់អាហារបង្អត់ស្អីនោះ ចង់ចាំតែប៉ុណ្ណោះឯង ។ ឧបមាយើងដាំបាយបានហើយ យើងលួចលាក់ដាំបាយ វាមិនឲ្យយើងស៊ីសោះ ។ វាមានបញ្ហាប៉ុណ្ណោះឯង ។

ដារ៉ា : ប៉ុន្តែដល់ពេលបាន..គឺថាជំនាន់ហ្នឹងវាតឹងណាស់អារឿងរៀបចំគ្រួសារ ។ ដល់ពេលពូបានរៀបចំគ្រួសារ ពូអរដែរទេពេលហ្នឹង?

សឿម ៖ អរហ្នឹងហើយ ។ ប៉ុន្តែអារឿងអញ្ចឹងគឺតាមគេបញ្ជាអញ្ចឹងទៅ ។ បើគេមិនឲ្យយើងនៅជាមួយគ្នា យើងក៏ត្រូវបែកគ្នាមួយរយៈទៅ ។ មានតែប៉ុណ្ណោះឯង ។ ប៉ុន្តែថា គេបើកឲ្យយើងរៀបការ ឧបមាថាយើងពេញចិត្តអ្នកណា យើងក៏សុំគេឲ្យស្នើឲ្យទៅ ។

ដាតា ៖ ចុះរៀបការនៅសម័យណោះអត់មានអ្នកណាគេបង្ខំយើងឲ្យរៀបការទេ?

សឿម ៖ អត់ទេ, ប្អូន ។ សម្រាប់ខ្ញុំ គឺចិត្តខ្លួនឯង ។ ហើយចិត្តខ្លួនឯងហើយ ក៏ទំនាក់ទំនងម៉ែឪគេ ។ នេះខ្លួនខ្ញុំណា ។ អត់ដូចពួកខាងភ្នំពេញដែលគេរត់មកទេ ។ ខ្លះបង្ខំមែន ។ បង្ខំខ្លួនឯងទេណា ប៉ុន្តែគេអត់បង្ខំទេ ។ បើនិយាយពីរឿងគ្រួសារគេអត់បង្ខំយើងទេ ។

ដាតា ៖ ចុះពូ កាលពេលដែលពូនៅលើកទំនប់នោះ មានជនជាតិវៀតណាមអីនៅជាមួយទេ?

សឿម ៖ ទេ, សម័យកាលណោះអត់ទាន់មានទេ ជនជាតិវៀតណាម ។

ដាតា ៖ ចុះចាមអី?

សឿម ៖ បើចាម ប្រហែលមាន ។ បើកាលដែលខ្ញុំនៅចល័តកាលណោះ មានតែពួកអារ៉ាប់ ។ វាមកដាំកប្បាសជាមួយនឹងកង វ៉ាល់ ហ្នឹងឯង ។ មានអារ៉ាប់មួយ ។

ដាតា ៖ ម៉េចទៅ? គេធ្វើអារ៉ាប់?

ដារ៉ា ៖ អារ៉ាប់នោះ វានៅផ្ទះវាទៅ គេឲ្យវាចល័តដែរ ។ ប៉ុន្តែគេអត់ដឹងវាថាវាយ៉ាងណាក៏មិនដឹង ។ នៅជាមួយខ្ញុំហ្នឹងទៅ និយាយជាមួយខ្ញុំហ្នឹង ឧបមាថាចបអញ្ចឹង គេប្រាប់ថាអញ្ចេះថាអញ្ចោះទៅណា ។ មានពួកអារ៉ាប់ម្នាក់ ។

ដាតា ៖ ហើយដល់ពេលក្រោយមក គាត់នៅតែ...

សឿម ៖ គាត់នៅបែកគ្នា មិនដឹងទៅនៅឯណាទេ ។ ពេលខ្ញុំបែកមកភូមិវិញ មិនថាទៅណា ឬគេយកទៅណាក៏មិនដឹង!

ដារ៉ា ៖ អារ៉ាប់នោះមកពីណា?

សឿម ៖ វាមកនៅផ្ទះខ្មែរយើងហ្នឹងឯង តែដល់ពេលចប់ទៅ...

ដារ៉ា ៖ ទេ, ដើមកំណើតវានៅឯណា?

ដាតា ៖ មកពីភ្នំពេញអី?

សឿម ៖ ទេវានៅផ្ទះខ្មែរនេះ ហើយទៅគេជន្លៀសមកតាមក្រោយ ។ ទៅវាមកនៅជាមួយខ្ញុំ ហើយសួរនាំ និយាយភាសាវាទៅ ។ សួរចបនិយាយថាអី ។ និយាយថា សាម៉ាល់ អាម៉េចទេ! (សើច) ។ កាលណោះមិនដឹងថាភាសាអី ។ ក៏វាប្រាប់ថាភាសាអារ៉ាប់ វាហ្នឹងអារ៉ាប់ ។

ដាវ៉ា ៖ ចុះពូរឿងរ៉ាវដែលពូបានទៅលើកទំនប់លើកអីនៅសម័យខ្មែរក្រហម តើពូមានបាននិយាយប្រាប់កូនចៅរបស់ពូរឿងហ្នឹងខ្លះដែរ?

សឿម ៖ មាននិយាយខ្លះដែរ ។ អារឿងលំបាកវេទនាយ៉ាងណា...

ដាវ៉ា ៖ ច្រើននិយាយពេលណាពូ?

សឿម ៖ ដូចថាកូនចៅវាដឹងខ្លះដែរទៅ វាដូចថាមិនចាំបាច់និយាយប្រាប់អីច្រើនទេ វាធ្លាប់ដឹងថាម៉ែឪលំបាកយ៉ាងម៉េច ។

ដាតា ៖ ពូ ពេលពូនិយាយរឿងហ្នឹងប្រាប់កូនពូអញ្ចឹង ពូច្រើនលើកឧទាហរណ៍អំពីអី?

សឿម ៖ ពេលនោះវាមិនចាំបាច់ឧទាហរណ៍អីទេ លើកតែពីការពិត មិនបាច់ឧទាហរណ៍ទេ ។ និយាយពីរឿងអត់យ៉ាងនេះមួយ យ៉ាងណោះមួយ ។

ដាតា ៖ និយាយពីរឿងអត់ហូប អត់អី?

សឿម ៖ ណោះឯង និយាយពីរឿងអត់ហូប ។ អារឿងពិបាក រឿងលួចលាក់ ។ ហើយពេលវាទៅឃើញ វាមិនឲ្យហូបទៀត ។ វាវេទនាអារឿងណោះឯង ហើយអារឿងបបរអីនោះ ។ ម្ហូបមិនគ្រប់គ្រាន់ ។ ធ្វើការមិនមានពេលឈប់ ពេលសម្រាក ។ វាមិនមានថ្ងៃអាទិត្យ ។ មានតែប៉ុណ្ណោះឯង ។ យើងសព្វថ្ងៃនេះ វាសេរី ។ វាមិនអាចដូចយើងសព្វថ្ងៃនេះទេ ។ យើងរស់ដោយសារគេឲ្យស៊ី ។ គេឲ្យស៊ីច្រើន យើងក៏អាចរស់ ។ ដល់ពេលគេមិនឲ្យស៊ីច្រើន យើងក៏គិតតែពីរឿងថ្ងៃស្លាប់តែប៉ុណ្ណោះ ។

ដាវ៉ា ៖ ពូមានអីដែលពូចង់ចាំច្បាស់ហើយចង់និយាយប្រាប់ខ្ញុំ ដែលរឿងរ៉ាវដែលពូភ្លេចមិនបានទាល់តែសោះ? មានរឿងអញ្ចឹងៗអីដែរពូ?

ដាតា ៖ រឿងដែលអត់ទាន់បានសួរអញ្ចឹងហ្នឹងណា?

សឿម ៖ ភ្លេចមិនបាន អារឿងរ៉ាវចង់ចាំនោះគឺអារឿងវេទនានេះឯង ។ អាវេទនា វាមិនឲ្យស៊ីមិនឲ្យចុកបបូរណ៍ ។ អាធ្វើបានហើយ វាមិនឲ្យយើងហូបគ្រប់គ្រាន់ ។ វេទនាតែរឿងហ្នឹងឯង ។

ដាវ៉ា ៖ ពូ, ខ្ញុំដូចជាអត់មានសំណួរអីតទៅទៀតទេ ហើយខ្ញុំសូមអរគុណច្រើនដែលពូបានផ្ដល់ព័ត៌មាន ។ បាទ, អរគុណពូ ។

សឿម ៖ បាទ ។

«ចប់»